# សេចក្តីប្រកាសព័ត៌មាន

**រាជធានីភ្នំពេញ ថ្ងៃទី ១១ ខែវិច្ឆិកា ឆ្នាំ២០១០**

**សម្រាប់ការផ្សព្វផ្សាយជាបន្ទាន់**

---

## របាយការណ៍បានរកឃើញថា "កូដកម្មមានលក្ខណៈស្របច្បាប់ភាគច្រើន ប្រតិកម្មរបស់និយោជកមិនមានលក្ខណៈសមាមាត្រ"

អត្ថបទវិភាគផ្នែកច្បាប់ឯករាជ្យមួយ ជុំវិញកូដកម្មធ្វើឡើងដោយកម្មកររោងចក្រកាត់ដេរនៅទូទាំងប្រទេសនាខែកញ្ញា ដែលចេញផ្សាយដោយមជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា ថ្ងៃនេះបានសន្និដ្ឋានថា សហជីពបានធ្វើកូដកម្មដោយគោរពតាមលក្ខខណ្ឌជាច្រើនដែលតម្រូវដោយច្បាប់។ របាយការណ៍នេះគាំទ្រចំពោះអំណះអំណាងរបស់សមាគមរោងចក្រកាត់ដេរកម្ពុជា (GMAC) ដែលថានិយោជក និងនិយោជិតមានសិទ្ធិទាក់ទងនឹងការធ្វើកូដកម្ម។ ទោះជាយ៉ាងនេះក្តី នៅទីបញ្ចប់នៃកូដកម្មនេះ គេបានរកឃើញថាអំណះអំណាងភាគច្រើនរបស់សមាគមរោងចក្រកាត់ដេរកម្ពុជាដែលថាកូដកម្មនេះខុសច្បាប់ មិនមានមូលដ្ឋានគ្រប់គ្រាន់ឡើយ។

របាយការណ៍នេះក៏បានធ្វើការសន្និដ្ឋានផងដែរថា សមាគមរោងចក្រកាត់ដេរកម្ពុជាពិតជាមានសិទ្ធិចោទជាសំណួរទាក់ទងនឹងការគោរពច្បាប់របស់សហជីព ប៉ុន្តែប្រតិកម្មរបស់សមាជិកខ្លួនដែលគំរាមប្តឹងពីបទព្រហ្មទណ្ឌ និងដាក់ពាក្យបណ្តឹងទៅតុលាការប្រឆាំងនឹងសមាជិកសហជីពមិនមានលក្ខណៈសមាមាត្រនោះទេ ហើយទោះបីជាក្នុងកាលៈទេសៈណាក៏ដោយ ក៏ទង្វើបែបនេះមិនសមស្របដែរ បើទោះបីជាអំណះអំណាងរបស់ពួកគេដែលថា កូដកម្មគឺខុសច្បាប់នោះ មានលក្ខណៈត្រឹមត្រូវយ៉ាងណាក៏ដោយ។

លោក អ៊ូ វីរៈ ប្រធានមជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជាបានអំពាវនាវឲ្យសហជីព និងនិយោជកជួបគ្នា និងធ្វើការជាមួយគ្នា ដើម្បីសម្រេចបាននូវដំណោះស្រាយជាវិជ្ជមានទៅលើវិវាទដែលស្មុគស្មាញនេះ ដោយលោកមានប្រសាសន៍ថា "ការវិភាគនេះបង្ហាញកាន់តែច្បាស់ថាបណ្តឹងផ្លូវច្បាប់ទៅតុលាការមិនអាចដោះស្រាយបញ្ហាបានទេ ផ្ទុយទៅវិញគឺធ្វើឲ្យស្ថានការណ៍កាន់តែអាក្រក់ទៅៗ។ ខ្ញុំសូមអំពាវនាវឲ្យនិយោជកដកពាក្យបណ្តឹងដែលនៅសេសសល់ទាំងអំបាលម៉ាន ហើយសម្រាប់សហជីពវិញ សូមឲ្យត្រលប់មកកាន់តុចរចា ដើម្បីប្រើប្រាស់គ្រប់ជម្រើសទាំងអស់ ដែលមានមុននឹងគំរាមកំហែងធ្វើកូដកម្មបន្តទៀត"។

របាយការណ៍នេះ បានកោតសរសើរចំពោះកិច្ចអន្តរាគមន៍ជាវិជ្ជមានរបស់រាជរដ្ឋាភិបាលកម្ពុជា ដែលបានព្យាយាមជម្រុញឲ្យគ្រប់ភាគីទាំងអស់ចូលរួមកិច្ចចរចាថ្មីៗបន្តទៀត ព្រមទាំងបាន

បង្កើតគណៈកម្មាធិការទ្វេភាគីថ្មីមួយ សម្រាប់ដោះស្រាយវិវាទដែលស្មុគស្មាញនេះ។ លោក អ៊ូ វីរៈ បានមានប្រសាសន៍ថា រដ្ឋាភិបាលចាំបាច់ត្រូវតែបន្តដើរតួនាទីក្នុងន័យស្ថាបនាក្នុងករណីនេះ ដើម្បីការពារសិទ្ធិរបស់ភាគីទាំងពីរ និងលើកទឹកចិត្តឲ្យមានការចរចាតាមដែលអាចធ្វើទៅបាន។

សិទ្ធិរបស់និយោជិតក្នុងការធ្វើកូដកម្ម មានចែងយ៉ាងច្បាស់នៅក្នុងច្បាប់សិទ្ធិមនុស្សអន្តរជាតិ រដ្ឋធម្មនុញ្ញកម្ពុជា និងច្បាប់ជាតិដទៃទៀត។ ប៉ុន្តែ សិទ្ធិនេះមិនមែនជាសិទ្ធិដាច់ខាតនោះទេ ហើយកូដកម្មអាចធ្វើទៅបាន លុះត្រាតែសហជីពគោរពតាមច្បាប់ដែលមានចែង និងនីតិវិធីក្នុងការរៀបចំកូដកម្ម។ បើទោះបីជាសមាគមរោងចក្រកាត់ដេរកម្ពុជាបានចោទប្រកាន់ថា សហជីពមិនបានគោរពតាមនិយាមច្បាប់ទាំងនោះក៏ដោយ ក៏ការវិភាគរបស់មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជាបានរកឃើញថា សហជីពបានជូនដំណឹងអំពីការធ្វើកូដកម្មដូចដែលមានកំនត់ក្នុងច្បាប់ ព្រមទាំងបានបំពេញរាល់កាតព្វកិច្ចរបស់ពួកគេនៅក្នុងនីតិវិធីផ្សះផ្សា ហើយកូដកម្មបានប្រព្រឹត្តទៅដោយអហិង្សា។

បើទោះបីជាកូដកម្មពិតជាបានបំពានលើលក្ខខណ្ឌច្បាប់មែនក៏ដោយ ក៏និយោជកមានកាតព្វកិច្ចឆ្លើយតបដោយមធ្យោបាយសមាមាត្រមួយ។ អត្ថបទវិភាគរបស់មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា សន្និដ្ឋានថា ប្រតិកម្មជាច្រើនរបស់និយោជកទៅនឹងកូដកម្មនាខែកញ្ញានោះគឺជាការខកខានមិនបានបំពេញលក្ខណៈសមាមាត្រនេះ។ លោក អ៊ូ វីរៈ បានលើកឡើងថា “ការគំរាមដាក់ទោសទណ្ឌព្រហ្មទណ្ឌ និងដាក់ពន្ធនាគារ ដើម្បីជាការឆ្លើយតបទៅនឹងកូដកម្មដោយសន្តិវិធី ព្រមទាំងការគំរាមដាក់ពាក្យបណ្តឹងប្រឆាំងនឹងសមាជិកសហជីពជាលក្ខណៈបុគ្គល គឺមិនសមហេតុផលនោះទេ។ និយោជកគួរតែលើកឡើងអំពីបញ្ហាដែលទាក់ទងនឹងភាពស្របច្បាប់ ដើម្បីនិយាយជាមួយសហជីពដោយផ្ទាល់”។

អត្ថបទវិភាគផ្នែកច្បាប់នេះជាភាសាខ្មែរ និងភាសាអង់គ្លេស មាននៅលើគេហទំព័រសិទ្ធិមនុស្សកម្ពុជា www.sithi.org និងគេហទំព័រមជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា www.cchrcambodia.org។

**សម្រាប់ព័ត៌មានបន្ថែម សូមទាក់ទង៖**


**លោក អ៊ូ វីរៈ** ប្រធានមជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា

ទូរស័ព្ទលេខ ៖ +៨៥៥ ១២ ៤០ ៤០ ៥១

អ៊ីម៉េល ៖ ouvirak@cchrcambodia.org

**លោក ចន ខូកលែន** ទីប្រឹក្សាជាន់ខ្ពស់ផ្នែកច្បាប់ មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា

ទូរស័ព្ទលេខ ៖ +៨៥៥ ៨៩ ៥៨ ៣៥ ៩០

អ៊ីម៉េល ៖ johncoughlan@cchrcambodia.org